Khmer | ភាសាខ្មែរ

# ដឹងពី ហានិភ័យរលកយក្សស៊ូណាមិរបស់អ្នក

## ស្វែងយល់អំពីហានិភ័យរលកយក្សស៊ូណាមិរបស់អ្នក



ទាក់ទងអង្គភាព NSW SES នៅតាមតំបន់របស់អ្នកដើម្បីទទួលបានព័ត៌មានអំពីរលកយក្សស៊ូណាមិនៅតាមតំបន់។

ដឹងពីតំបន់ជម្លៀងរលកយក្សស៊ូណាមិរបស់អ្នក ដោយពិនិត្យមើលឡើង វិញ **ផែនទីតំបន់ជម្លៀង** នៅលើ**គេហទំព័រ NSW SES៖**

www.ses.nsw.gov.au/tsunamisafe/evacuation-map/tsunami-evacuation-map

## ដឹងអំពីសញ្ញា និងផលវិបាកនៃរលកយក្សស៊ូណាមិ

រលកយក្សស៊ូណាមិ គឺជាស៊េរីនៃរលកដ៏មានឥទ្ធិពលដែលមានផលប៉ះពាល់ដល់តំបន់ឆ្នេរសមុទ្រក្នុងរយៈពេលមួយ ហើយចរន្តរលកយក្សស៊ូណាមិដ៏គ្រោះថ្នាក់អាចអូសបន្លាយជាច្រើនថ្ងៃបន្ទាប់ពីផលប៉ះពាល់ដំបូង។

មានសញ្ញាធម្មជាតិជាច្រើននៃរលកយក្សស៊ូណាមិ ឧទាហរណ៍៖

- **រញ្ជួយដី**
- **អាការៈសមុទ្រមិនធម្មតា៖ មើលទៅដូចជាទឹកជំនន់ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ឬជញ្ជាំងទឹក ឬកម្រិតទឹកសមុទ្រធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់បង្ហាញឃើញបាតសមុទ្រ**
- **សំឡេងរន្ទឺខ្លាំងចេញពីមហាសមុទ្រ ស្រដៀងនឹងសំឡេងរថភ្លើង**

រលកយក្សស៊ូណាមិមានផលប៉ះពាល់ និងផលវិបាកជាច្រើន ដូចជា៖

- **រលក ការឡើងកញ្ជ្រោលនៃទឹករលក និងចរន្តទឹកសមុទ្រធ្វើឱ្យខូចខាតខ្លាំង និងមានផលប៉ះពាល់ខ្លាំង**
- **រលកដែលអាចធ្វើដំណើរកាន់តែឆ្ងាយចូលទៅកាន់ទីដីដែលនៅឆ្ងាយពីសមុទ្រ ហើយកាន់តែមានលក្ខណៈបំផ្លិចបំផ្លាញកាន់តែច្រើនថែមទៀត**
- **ការលិចដោយទឹកជំនន់លើតំបន់នានានៅតាមឆ្នេរសមុទ្រទំនាប គឺអាចមានសម្រាប់ចម្ងាយលើសពី 2 គីឡូម៉ែត្រ ផ្ទែកព័ទ្ធដោយដី**
- **ទន្លេ និងអូរដែលហូរទៅមហាសមុទ្រអាចប្រឈមនឹងរលកដែលធ្វើដំណើរឡើង និងហ៊ុំព័ទ្ធជុំវិញក្បាលដី និងកោះនានា**

ក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយក្នុងគ្រាអាសន្នដោយសារទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES តាមលេខ 132 500។**

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

# ដឹងពី ហានិភ័យរលកយក្សស៊ូណាមិរបស់អ្នក

NSW STATE EMERGENCY SERVICE

## ត្រៀបជាស្រេច




ទាញយកកម្មវិធីគ្រោះថ្នាក់នៅជិតខ្ញុំ **Hazards Near Me** app ដាក់ក្នុងឧបករណ៍ចល័តរបស់អ្នក និងបង្កើត **តំបន់ឃ្លាំមើល** សម្រាប់តំបន់នានាដែលអ្នករស់នៅ ធ្វើការ និងទៅទស្សនា។



រៀបចំ **ផែនការជម្លៀសរលកយក្សស៊ូណាមិ** សម្រាប់ផ្ទះ អាជីវកម្ម និងទ្រព្យសម្បត្តិនានារបស់អ្នកដែលស្ថិតនៅក្នុងតំបន់ហានិភ័យរលកយក្សស៊ូណាមិ ហើយធ្វើឱ្យប្រាកដថាអ្នករៀបចំផែនការសម្រាប់មនុស្ស និងសត្វទាំងអស់ដែលស្ថិតនៅក្នុងការថែទាំរបស់អ្នក។



ចែករំលែកផែនការសង្គ្រោះបន្ទាន់របស់អ្នកជាមួយគ្រួសារ អ្នកជិតខាង និងសហការី ហើយពិនិត្យវាឡើងវិញជាប្រចាំ។

## រៀបចំកញ្ចប់សង្គ្រោះបន្ទាន់

កញ្ចប់សង្គ្រោះបន្ទាន់របស់អ្នកត្រូវតែមាន៖

- វិទ្យុចល័តដែលមានថ្មបម្រុងទុក
- ពិលដែលមានថ្មបម្រុង
- កញ្ចប់សង្គ្រោះបឋម (ជាមួយនឹងការផ្គត់ផ្គង់ចាំបាច់សម្រាប់គ្រួសាររបស់អ្នក)
- ទៀន និងឈើគូសមិនជ្រាបទឹក
- ឯកសារសំខាន់ៗ រួមមាន លេខទូរសព្ទទំនាក់ទំនងក្នុងគ្រាអាសន្ន
- ច្បាប់ចម្លងនៃផែនការក្នុងគ្រាមានអាសន្នទាំងអស់
- ថង់មិនជ្រាបទឹកសម្រាប់ដាក់វត្ថុមានតម្លៃ។



ក្នុងស្ថានភាព គំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយក្នុងគ្រាអាសន្នដោយសារ ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES តាមលេខ 132 500**។

www.ses.nsw.gov.au/languages

@NSWSES NSWSES NSWSES